# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា

Cambodia Watchdog Council

## សេចក្តីថ្លែងការណ៍

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ តំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា បានដឹកនាំក្រុមការងារចុះទៅពិនិត្យផ្ទាល់នៅកន្លែងដីមានទំនាស់របស់ប្រជាពលរដ្ឋ និងបង្គោលព្រំដែនលេខ ១១៤ ដល់ លេខ១១៩ ស្ថិតនៅភូមិសាស្ត្រ ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ហើយក៏បានជួបសំណេះសំណាលជាមួយតំណាងប្រជាពលរដ្ឋ ដែលរងគ្រោះប្រមាណជា១០៦គ្រួសារ។

តំណាងប្រជាពលរដ្ឋរងគ្រោះបានអះអាងប្រាប់ក្រុមការងាររបស់ ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ថា: ការបោះបង្គោលព្រំដែនពីលេខ១១៤ ដល់ លេខ១១៩ មានភាពមិនប្រក្រតីច្រើន ដែលធ្វើឲ្យពួកគាត់បាត់បង់ដីអាស្រ័យផល ទៅខាងភាគីយួន ជាច្រើនរយហិចតា ហើយបើគិតពីបន្ទាត់ព្រំដែនចាស់មកដល់ការបោះបង្គោលឡាក់ និងបង្គោលរណបថ្មី បានចូលមកប្រហែល៥០០ម៉ែត្រ ក្នុងទឹកដីកម្ពុជា។ នៅក្នុងនោះដែរក៏លោកយាយ និងលោកតាមានវ័យចំណាស់អាយុជាង៧០ឆ្នាំ បានរៀបរាប់ពីប្រវត្តិព្រំដែនរវាងកម្ពុជា និងយួនកាលនោះក្នុងទសវត្ស ៧០ថា ព្រំដែនខ្មែរនៅដល់ប៉ុស្តិ៍ចាំហាយ ហើយខ្សែបន្ទាត់ព្រំដែនចេះតែរំកិលបន្តិចម្តងៗចូលមកទឹកដីកម្ពុជាប្រមាណ៣គីឡូម៉ែត្រ បច្ចុប្បន្ននេះ។

តំណាងពលរដ្ឋបានបន្តអះអាងថា ដីដែលអាជ្ញាធរហាមឃាត់ពួកគាត់មិនឲ្យអាស្រ័យផល គឺជាដីកេរ្តិ៍ដូនតារបស់ពួកគាត់យូមកហើយ ដែលពួកគាត់បានកាន់កាប់ និងអាស្រ័យផលនៅលើដីនេះ។ នៅពេលក្រុមការងារគណកម្មាធិការព្រំដែនកម្ពុជា និងយួន បានស្នើសុំឲ្យពួកគាត់ផ្អាកការបង្កបង្កើនផលលើដីនោះ ជាបណ្តោះអាសន្នសិន រងចាំការបោះបង្គោលរួចរាល់សិន ទើបឲ្យពួកគាត់ធ្វើស្រែចម្ការលើដីនោះវិញ។ ប៉ុន្តែនៅពេលប្រជាពលរដ្ឋ ទៅបង្កបង្កើនផលនៅលើដីទំហំ៦០ហិចតា របស់ពួកគាត់ត្រូវបានអាជ្ញាធរស្រុកពញាក្រែក រារាំងនិងបណ្តេញ ពួកគាត់ចេញមិនឲ្យដាំដុះលើដីនោះ។ លើសពីនេះអាជ្ញាធរយួនក៏បានមកចូលរួមប

អាសយដ្ឋាន:ផ្ទះលេខ១២បេ ផ្លូវលេខ៥ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ
Address;#12B Str:5 Phoum Toulrokar Sangkat Chack Angre Kroum ,Khan mean Chey,Phnom penh
Tel/Fax(855 23) 217 544 / (855) 012 930 706 CCUsecretariat@gmail.com .www.facebook.com/rong chhun8

ណ្តោញ និងរុញច្រានប្រជាពលរដ្ឋខ្មែរ ដែលរងគ្រោះពីដីធ្លី ចូលប្រមាណជា២០០ម៉ែត្រ ក្នុងដីខ្មែរ ដែលអាជ្ញាធរខ្មែរ មិនបានទប់ស្កាត់ចំពោះទង្វើអាជ្ញាធរយួនធ្វើមកលើពលរដ្ឋរងគ្រោះ។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា យល់ឃើញថាប្រជាពលរងគ្រោះដែលបានបាត់បង់ដីធ្លី ជាច្រើនទៅភាគីយួនបន្ទាប់ពីបោះបង្គោលព្រំដែនរួច នៅសល់ដីតិចតួចគួរត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ផ្តល់សិទ្ធិឲ្យពួកគាត់អាស្រ័យផលនៅលើដីនោះ។ លើសពីនេះ ចំពោះទង្វើរបស់អាជ្ញាធរយួន ដែលរុញច្រានប្រជាពលរដ្ឋខ្មែរចូលប្រមាណជា២០០ម៉ែត្រក្នុងទឹកដីខ្មែរ គឺជាការរំលោភបំពានមកលើអធិបតេយ្យភាព នៃកម្ពុជា។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ស្នូមឲ្យរាជរដ្ឋាភិបាលកម្ពុជា ពង្រឹងនូវកងកម្លាំងការពារតាមខ្សែបន្ទាត់ព្រំដែនកុំឲ្យកម្លាំងអាជ្ញាធរប្រទេសជិតខាងចូលមកក្នុងដែនអធិបតេយ្យភាព នៃកម្ពុជាយើងបន្តទៀត និងត្រូវផ្តល់ដីទំហំប្រមាណ៦០ហិចតា ដែលកំពុងមានជម្លោះជូនប្រជាពលរដ្ឋធ្វើស្រែចម្ការ និងផ្តល់កម្មសិទ្ធិជូនពួកគាត់វិញ៕

ថ្ងៃអង្គារ ១កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

*រាជធានីភ្នំពេញ* ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០

**តំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា និង**
**ជាប្រធានសហភាពសហជីពកម្ពុជា**

CAMBODIAN CONFEDERATION OF UNIONS

**រ៉ុង ឈុន**

អាស័យដ្ឋានៈផ្ទះលេខ១២បេ ផ្លូវលេខ៥ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ
Address;#12B Str:5 Phoum Toulrokar Sangkat Chack Angre Kroum ,Khan mean Chey,Phnom penh
Tel/Fax(855 23) 217 544 / (855) 012 930 706 CCUsecretariat@gmail.com .www.facebook.com/rong chhun8